# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ២២៩ "ក្រ៤ ប"

ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩

-សំណុំរឿងព្រហ្មទណ្ឌលេខ ៥១២៣

ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧

-សំណុំរឿងស៊ើបសួរលេខ ៣១៧៦

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧

-សំណុំរឿងជំនុំជម្រះលេខ ៣៨៨០

ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ៨ និង ០០ នាទីព្រឹក នៅសាលសវនាការទី៣ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោកចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា

-លោកចៅក្រម ជាចៅក្រមប្រឹក្សា

-លោកចៅក្រម ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥១២៣ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ ដែលមាន**ជនជាប់ចោទ៖**

-ឈ្មោះ [redacted] **ឈេល** ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបរ សន្តិសុខ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ធំ មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួល ភូមិចោមចៅ២ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]ឆាំ "រ" ម្ដាយឈ្មោះ [redacted] សារីម "ស" ប្រពន្ធឈ្មោះ [redacted] គា មានកូន ០១នាក់ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៦៥៦ "ច" ដ.ឃ.ដ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ ។

-ដោយមានកញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស (គ្រឹះសោរបន្ទប់)** ប្រព្រឹត្តនៅចំណុចភូមិចោមចៅ២ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩-១០-១១ ខែសីហា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]សាវ៉ាន់ ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិចោមចៅ២ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី ០៩-១០-១១ ខែសីហា ឆ្នាំ២០១៧ មានករណីលួចមានស្ថានទម្ងន់ទោស (គ្រឹះសោរបន្ទប់ជួល) នៅចំណុចភូមិចោមចៅ២ សង្កាត់ចោមចៅ ដែលបង្កឡើងដោយជនសង្ស័យម្នាក់ឈ្មោះ [redacted] ឈេល ភេទប្រុស អាយុ២៣ឆ្នាំ ។ នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ ជនសង្ស័យបានគ្រឹះសោរបន្ទប់របស់ជនរងគ្រោះឈ្មោះ [redacted] សាវ៉ាន់ លួចបានអាវចំនួន ០៩ ។ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ ជនសង្ស័យបានគ្រឹះសោរបន្ទប់របស់ជនរងគ្រោះដដែល លួចបានខោចំនួន ០១ ។ លុះដល់ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ជនរងគ្រោះបានដាក់ទូរស័ព្ទដើម្បីថតវីដេអូទុកចោល ក៏ស្រាប់តែ



Scanned with CamScanner

ឃើញជនសង្ស័យផ្ដិះសោរទ្វារបន្ទប់របស់ជនរងគ្រោះ ហើយលួចបានខោចំនួន ០២ ។ ជនរងគ្រោះឃើញដូច្នេះ ក៏បានប្តឹងសមត្ថកិច្ច រួចសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យ រួចកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីតែម្តង ។

-បានឃើញ របាយការណ៍សំយោគលេខ ៣៤៤/១៧ រ.ប.ក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ នៃស្នងការដ្ឋាននគរបាលធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៧១៩ អ.យ.ឆ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ របស់លោក[redacted] តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៤៤៨៣ “ច” ដ.ជ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ របស់លោក[redacted]ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ឈេឈល បានឆ្លើយថា ៖ កាលពីថ្ងៃទី ០៩-១០-១១ ខែសីហា ឆ្នាំ២០១៧ ខ្លួនបានចូលក្នុងបន្ទប់របស់ជនរងគ្រោះ ហើយបានធ្វើសកម្មភាពលួចយកខោចំនួន ០៣ និងអាវចំនួន ០៩ ។ ដោយរាល់ដងមុនពេលចូលក្នុងបន្ទប់នោះខ្លួនបានផ្ដិះសោរបន្ទប់ រួចលួចយកខោអាវ។ លុះនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៧ ជនរងគ្រោះបានចាប់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង ។

-ក្រឡាបញ្ជីអានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]សាវ៉ាន់ មានខ្លឹមសារថា៖ កាលពីថ្ងៃទី ០៩-១០-១១ ខែសីហា ឆ្នាំ២០១៧ មានគេចូលមកគាស់ទ្វារបន្ទប់ជួលរបស់ខ្លួន ហើយលួចសំលៀកបំពាក់ ដោយឃើញដូច្នេះខ្លួនបានដាក់ទូរស័ព្ទថតវីដេអូរទុកចោលនៅក្នុងបន្ទប់ជួល ហើយចេញទៅធ្វើការធម្មតា ។ ពេលខ្លួនត្រលប់មកវិញ បើកទូរស័ព្ទមើល ស្រាប់តែឃើញឈ្មោះ [redacted] ឈេឈល បានកក្កូរកកាយយកសម្ភារៈនៅក្នុងបន្ទប់ជួលរបស់ខ្លួន ។ បន្ទាប់មកខ្លួនបានទៅឆែកឆេរនៅក្នុងបន្ទប់របស់ឈ្មោះ [redacted] ឈេឈល ឃើញមានសំលៀកបំពាក់របស់ខ្លួនចំនួន ១១ រួចខ្លួនក៏បានប្តឹងសមត្ថកិច្ចតែម្តង ។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ[redacted]សារឿន មានខ្លឹមសារថា៖ កាលពីថ្ងៃទី ០៩-១០-១១ ខែសីហា ឆ្នាំ២០១៧ មានគេចូលមកគាស់ទ្វារបន្ទប់ជួលរបស់ឈ្មោះ[redacted] សាវ៉ាន់ លួចយកសំលៀកបំពាក់អស់មួយចំនួន បន្ទាប់មកគេបានបើកទូរស័ព្ទមើល កាមេរ៉ាស្រាប់តែឃើញឈ្មោះ[redacted] ឈេឈល បានកក្កូរកកាយយកសម្ភារៈនៅក្នុងបន្ទប់ជួលរបស់គេ ។ បន្ទាប់មកគេបានទៅឆែកឆេរនៅក្នុងបន្ទប់របស់ឈ្មោះ [redacted] ឈេឈល ឃើញមានសំលៀកបំពាក់មួយចំនួនរួចក៏បានប្តឹងសមត្ថកិច្ចតែម្តង។

## សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្រោយពីបានស្ដាប់ការសួរដេញដោលនាពេលសវនាការ និងពិនិត្យឯកសាររួចមក ឃើញថា ពិតជាមានបទល្មើស លួចមានស្ថានទម្ងន់ទោស (ផ្ដិះសោរទ្វារបន្ទប់) ប្រព្រឹត្តដោយឈ្មោះ [redacted] ឈេឈល ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ប្រាកដមែន ដោយមានភស្តុតាងដាក់បន្ទុក ចម្លើយរបស់ជនជាប់ចោទ ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងចម្លើយសាក្សី ហេតុដូចនេះតំណាងអយ្យការសុំតម្កល់បទចោទប្រកាន់តាមដីកា



Scanned with CamScanner

សន្និដ្ឋានស្ដាពរលេខ ៣៧១៩ អ.យ.ធ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ ទុកជាបានការដដែល និងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-កញ្ញាមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានការពារថា៖ ស្នើសុំឱ្យតុលាការប្ដូរបទចោទពីបទលួច តាមមាត្រា ៣៥៣ , ៣៥៧ មកមាត្រា ៣៥៣ , ៣៥៦ វិញ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ឈេល បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្ដាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តាមរបាយការណ៍សំយោគលេខ ៣៤៤/១៧ រ.ប.ក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ បានបញ្ជាក់ថា ពិតជាមានករណី **លួចមានស្ថានទម្ងន់ទោស (ផ្ដិះសោរទ្វារបន្ទប់)** កាលពីថ្ងៃទី ០៩-១០-១១ ខែសីហា ឆ្នាំ២០១៧ នៅចំណុចភូមិចោមចៅទី២ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដែលបង្កឡើងដោយឈ្មោះ [redacted] ឈេល ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ប្រាកដមែន ។

២-តុលាការបានទទួលសំណុំរឿងមកជំនុំជម្រះ ដែលមានជនជាប់ចោទឈ្មោះ [redacted] ឈេល ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជម្រះលេខ ៤៤៨៣ “ច” ដ.ជ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ ពីបទ លួចមានស្ថានទម្ងន់ទោស (ផ្ដិះសោរទ្វារបន្ទប់) បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ដែលចែងថា “អំពើលួចមានស្ថានទម្ងន់ទោស” ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ០៣ឆ្នាំ(បីឆ្នាំ) ទៅ ១០ឆ្នាំ(ដប់ឆ្នាំ) ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឈេល បានឆ្លើយថា៖ នៅថ្ងៃកើតហេតុនោះ ខ្លួនពិតជាបានធ្វើសកម្មភាពផ្ដិះសោរទ្វារបន្ទប់ជួល ហើយលួចយកសំលៀកបំពាក់របស់ជនរងគ្រោះប្រាកដមែន ។

៤-តាមអំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាវ៉ាន់ និងអំណានចម្លើយសាក្សីឈ្មោះ [redacted] សារឿន បានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ នៅថ្ងៃកើតហេតុ មានគេចូលក្នុងបន្ទប់ជួលរបស់ខ្លួន ហើយលួចសំលៀកបំពាក់របស់ខ្លួនអស់មួយចំនួន ក្រោយមកខ្លួនបើកកាមេរ៉ាឃើញឈ្មោះ [redacted] ឈេល បានចូលមកបន្ទប់ខ្លួនរើកកាយសម្ភារៈ ។ បន្ទាប់មកខ្លួនក៏បានទៅឆែកឆេរបន្ទប់របស់គេឃើញសំលៀកបំពាក់ រួចក៏ប្ដឹងសមត្ថកិច្ចតែម្ដង ។



Scanned with CamScanner

៥-តាមចម្លើយសារភាពរបស់ជនជាប់ចោទ, អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ព្រមទាំងឯកសារពាក់ព័ន្ធ អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ឈេយល ពិតជាបានប្រព្រឹត្តអំពើល្មើសប្រាកដមែន ។

៦-អំពើរបស់ជនជាប់ចោទ ដែលបានធ្វើសកម្មភាពគ្លុះសោរទ្វារបន្ទប់ ហើយលួចយកសម្ភារៈរបស់ជនរងគ្រោះ ដែលអំពើនេះ គឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៧-ជនជាប់ចោទឈ្មោះ [redacted] ឈេយល ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ជាកំណត់អាយុដែលអាចទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ហើយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ ដូចនេះជននេះប្រាកដជាយល់ដឹងថា អំពើរបស់ខ្លួនពិតជាប៉ះពាល់ធ្ងន់ធ្ងរដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ។

៨-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការប្តឹងសុំតម្កល់ការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៧១៩ អ.យ.ឆ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ ទុកជាបានការដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៩-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ឈេយល ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ពីបទ លួចមាន**ស្ថានទម្ងន់ទោស (គ្លុះសោរទ្វារបន្ទប់)** ប្រព្រឹត្តនៅចំណុចភូមិចោមចៅទី២ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩-១០-១១ ខែសីហា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១០-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានខាងលើ គប្បីតុលាការពិចារណា ។

១១-សំដីចុងក្រោយរបស់ជនជាប់ចោទសំណូមពរថា សូមឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួន។

១២-ដើមបណ្តឹងរដ្ឋប្បវេណីមិនបានប្តឹងសុំទាមទារសំណងអ្វីទេ ដូចនេះគប្បីតុលាការពុំចាំបាច់លើកយកបញ្ហាសំណងមកពិចារណាសម្រេចឡើយ ។

## ហេតុដូច្នេះសម្រេច

-ផ្តន្ទាទោសលើឈ្មោះ [redacted] ឈេយល ភេទប្រុស អាយុ២៣ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០៣ (បី) ឆ្នាំ ។

ពីបទ លួចមានស្ថានទម្ងន់ទោស (គ្លុះសោរទ្វារបន្ទប់) ប្រព្រឹត្តនៅចំណុចភូមិចោមចៅទី២ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩-១០-១១ ខែសីហា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឈេយល និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ យ៉ន់ សាវ៉ាន់ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ ។

-គូភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

.............................................................................................................................

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩
ក្រឡាបញ្ជី
[redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]



Scanned with CamScanner